ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍

## ស្តីពី

## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំខែឧសភា ឆ្នាំ២០១៤

### I- សភាពការណ៍រួម

ក្នុងខែឧសភា ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុនាដើមរដូវវស្សានេះមិនទាន់មានអំណោយផលល្អប្រសើរនៅឡើយទេ បរិមាណទឹកភ្លៀងធ្លាក់ជាមធ្យមនិងតិចតួចនៅតាមតំបន់នៃរាជធានី ខេត្ត ដោយទទួលឥទ្ធិពលនៃខ្យល់មូសុងសម្ពាធទាបបក់ពីទិសនិរតី។ ទោះបីទឹកភ្លៀងមិនទាន់អំណោយផលល្អប្រសើរយ៉ាងណាក៏ដោយ ក៏ប្រជាកសិករទូទាំងប្រទេសបានត្រៀមលក្ខណៈជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការចាប់ផ្តើមការងារបង្កបង្កើនផលស្រូវរដូវវស្សាមានជាអាទិ៍ ការរៀបចំដីភ្ជួររាស់ សាបព្រោះ ដក ស្ទូង ដោយសម្រេចលទ្ធផលបានប្រមាណ ១៥,៨៧ភាគរយ នៃផែនការដាំដុះ២.៤១១.៨០៧ហិកតា។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

### II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

#### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៦៤៣.៣៩៦ហិកតា (ក្នុងនោះគោ-ក្របីចំនួន៦៧.០៣៤ហិកតា ស្មើនឹង១០,៤២% និងគ្រឿងយន្តចំនួន៥៧៥.០៦២ហិកតា ស្មើនឹង៨៩,៣៨%) តិចជាងឆ្នាំមុនចំនួន៣១.៩២៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន១៣០.៣៧២ហិកតា

-ផ្ទៃដីសាបសរុបចំនួន២.៨៥៩ហិកតា តិចជាងឆ្នាំមុនចំនួន១១.១៥៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន១៧.៨៦១ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៣៨២.៨៣២ហិកតា ស្មើនឹង១៥,៨៧ភាគរយ នៃផែនការ២.៤១១.៨០៧ហិកតា លើសឆ្នាំមុនចំនួន៩១.៦១៦ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១៩.០២៩ហិកតា

- ស្រូវស្រាលចំនួន១៤០.៩៤៤ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១០៦.១៦៣ហិកតា) លើសឆ្នាំមុនចំនួន១៦.២៤៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១៨.៥៩៣ហិកតា
- ស្រូវកណ្តាលចំនួន១០៥.៩៩២ហិកតា លើសឆ្នាំមុនចំនួន៥៣.០១៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន២៤.៨៣៤ហិកតា
- ស្រូវធ្ងន់ចំនួន៩០.៤២១ហិកតា លើសឆ្នាំមុនចំនួន២៤.៨៤០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១៤ហិកតា
- ស្រូវចម្ការចំនួន១៥.២៦៧ហិកតា លើសឆ្នាំមុនចំនួន៥.៨៧៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៣.៩៩០ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- ស្រូវឡើងទឹកចំនួន៣០.៦០៨ហិកតា តិចជាងឆ្នាំមុនចំនួន៨.៣៦៥ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ២៨.៤០១ហិកតា។

**១.២ ដំណាំរួមផ្សំ**

ផ្ទៃដីសម្រេចបានចំនួន៣៣២.១០៨ហិកតា ស្មើនឹង៦២,៩៣% នៃផែនការចំនួន៥២៧,៧៧៧ហិកតា លើសឆ្នាំមុនចំនួន១៣.៨៣០ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន៣២.៣៩២ហិកតា (ក្នុងនោះពោតក្រហម២១.៩៤៧ហិកតា) តិចជាងឆ្នាំមុន៣១.៩៦៣ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន២៦៥.៦០៩ហិកតា លើសឆ្នាំមុន៥១.៩១៦ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន១.០២៣ហិកតា តិចជាងឆ្នាំមុន៣៥៩ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន៩.៥៩០ហិកតា តិចជាងឆ្នាំមុន១.១១៧ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន២៣.៤៩៤ហិកតា តិចជាងឆ្នាំមុន៤.៦៤៧ហិកតា ។

**១.៣ ដំណាំឧស្សាហកម្ម**

ផ្ទៃដីសម្រេចបាន៣៨.៣៤៦ហិកតា ស្មើនឹង២៤,៤៣% នៃផែនការ១៥៦.៩៦៥ហិកតា តិចជាងឆ្នាំមុន៧.២១២ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន៦.៧៥៥ហិកតា តិចជាងឆ្នាំមុន២.៧៥២ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន៥.៤២២ហិកតា លើសឆ្នាំមុន៤.៨៩៩ហិកតា

-ផ្ទៃដីល្ងចំនួន១៥.៥៤៥ហិកតា តិចជាងឆ្នាំមុន៩.៧៤២ហិកតា

-ផ្ទៃដីអំពៅចំនួន១០.៥០៥ហិកតា លើសឆ្នាំមុន៣៧២ហិកតា

-ផ្ទៃដីក្រចៅចំនួន៦៨ហិកតា លើសឆ្នាំមុនចំនួន៥ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន៥១ហិកតា លើសឆ្នាំមុន៦ហិកតា។

**២ ផ្នែកកៅស៊ូ**

**២.១ ការធ្វើអាជីវកម្ម ផលិតកម្មកៅស៊ូ**

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៤១,៤៣ | - |
| | សរុប I | ៤០៦,៦០ | ៣៤៤,៣១ | ១៤១,៤៣ | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ៥.៧៥៨,៥៨ | ២.០៤៤,០០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៣៦៧,៣៥ | ១.៦២៥,៩០ | ៣៧៩,៨០ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ៨៨៥,០១ | ២៧៨,៧០ | ១០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ១.៤៣៧,៤៧ | ៩៣៨,៨០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.១២៨,២១ | ១.៥១៤,៣៣ | ៥៥១,២០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វារីសសស៍ (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ៤៤៦,៤៦ | ៣៧២,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១៥៩,០០ | ៣៨៩,៩៦ | ៣១៤,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៤៧៦,១៥ | ២៩៦,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.០៧៧,៩២ | ១.៦៨០,៨២ | ៨៤០.០០ |
| | សរុប II | ២៥.៦២០,១៧ | ២៨.៨៥៣,៥៧ | ១២.៣៦២,២៧ | ៥.៤៥៦,០០ |

| | | | | | |
|---|---|---|---|---|---|
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៥២.៥១៦,០០ | ៨៤.៩១២,០០ | ១៦.៩៥៧,០០ | ១៦.៩៥៧,០០ |
| សរុប III | | ៥២.៥១៦,០០ | ២២០.៣៥៨,០០ | ១៦.៩៥៧,០០ | ១៦.៩៥៧,០០ |
| សរុប I+II+III | | ៧៨.៥៤២,៧៧ | ២៤៩.៥៥៥,៨៨ | ២៥.៤៦០,៧០ | ២២.៤១៣,០០ |

### ២.២ ការស្រាវជ្រាវ ការផ្សព្វផ្សាយ បណ្តុះបណ្តាល និងសកម្មភាពផ្សេងៗទៀត

-បានចាត់មន្ត្រីជំនាញឲ្យទៅបណ្តុះបណ្តាលបច្ចេកទេសចៀរជ័រដល់អ្នកចៀរជ័រកៅស៊ូនៅប្រទេសមីយ៉ាន់ម៉ា តាមការស្នើសុំរបស់ប្រទេសនេះ

-វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅចម្ការកៅស៊ូក្រែក ខេត្តត្បូងឃ្មុំ បានចំនួន៤ឡូត៍ពិសោធន៍ នៅលើផ្ទៃដី២០ហិកតា ដើម្បីស្រាវជ្រាវអំពីការបង្កាត់ពូជ

-ចុះប្រមូលទិន្នន័យចម្ការពិសោធន៍នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក ខេត្តត្បូងឃ្មុំ ដើម្បីស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-បញ្ចូលទិន្នន័យចម្ការពិសោធន៍ ស្រង់ទិន្នន័យផលជ័រគ្រប់ចម្ការពិសោធន៍ និងរៀបចំទិន្នន័យឧតុនិយម ដើម្បីស្រាវជ្រាវ ការដាំដុះ និងការពារ

-តម្លើងឧបករណ៍ធ្វើតេស្តផលិតផលពីកៅស៊ូជាមួយជំនាញការនៃអង្គការ UNIDO សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរពិសោធន៍

-ការងារនៅស្ថានីយអនុវត្តៈ បំបៅកូនកៅស៊ូលើកទី១បានចំនួន៩ពូជ សរុបចំនួន៣.៤៦៧ដើម និងលើកទី២បានចំនួន១.៣១៧ដើម និងជំរះស្មៅវែករងកៅស៊ូដាំឆ្នាំ២០០៨-២០១៣ បានចំនួន១៨៧,៥០ហិកតា។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣៩៧ក្បាល ក្នុងនោះជ្រូកបាចំនួន១៤ក្បាល ជ្រូកមេចំនួន១០៦ក្បាល និងកូនជ្រូកចំនួន១៣២ក្បាល

-គោសរុបចំនួន២០៣ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥៣ក្បាល គោបៅដោះចំនួន៤៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន២៣.៧១៩ក្បាល ជំងឺអុតក្តាមចំនួន១.២៧៨ក្បាល និងជំងឺបូសខ្យល់ចំនួន៩១ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន១០១សំណាក។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានប្រជុំពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីកម្រិតអន្តរក្រសួងចំនួន២លើក

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន៤ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស

-ធ្វើការឃាត់ចាប់បទល្មើស៦ករណី ដោយឃាត់ចាប់ជ្រូកចំនួន៤៧ក្បាល មាន់ចំនួន២.១៩២ក្បាល ស៊ុតចំនួន២៧.០០០គ្រាប់ ផលិតផលខូចគុណភាពចំនួន៤.៤៩០គីឡូក្រាម និងធ្វើការដាក់ពិន័យជាទឹកប្រាក់ចំនួន២៤.០០០.០០០រៀល

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន២កន្លែង ក្របីចំនួន២កន្លែង ជ្រូកចំនួន១០លើក មាន់ចំនួន៤១កន្លែង ទាចំនួន៥៥កន្លែង កន្លែងពិឃាតមានចំនួន២០លើក កន្លែងលក់មានចំនួន២៨លើក ទ្រុងចិញ្ចឹមចំនួន៧៥លើក បរិវេណភូមិចំនួន១៣លើក សត្តឃាតដ្ឋានចំនួន២៧លើក និងផ្លូវជាតិចំនួន១លើក

-ចាត់ក្រុមអន្តរភាគមន៍ចុះប្រតិបត្តិការជាប្រចាំដើម្បីធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ ដោយបានអនុវត្តវិធានការបសុពេទ្យជាក់ស្តែង ព្រមទាំងបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៣.៥ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន១៥២ឡ។

## ៤ ផ្នែករុក្ខាប្រមាញ់

### ៤.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិចំនួន៥.៧៤៧.៧៦៣.៧៣០រៀល និងផ្តល់សេវាសាធារណៈចំនួន១៣៧.៣០៧,៥៧ដុល្លារ និង៦.១០២.៦១០.៧៨៨រៀល។

### ៤.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន២២.២៥៩,០០១ម៣ ឈើជ្រុងចំនួន៨៩,៧៥១ម៣ កូនឈើចំនួន១៥.៨៨៥ដើម អុសចម្រុះចំនួន១.៣៨០ស្ទែរ ជ័រទឹកចំនួន២២៩តោន និងគ្រាប់សំរ៉ែងចំនួន២.០៦២គីឡូក្រាម។

### ៤.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួនប្រមាណ ១៩៣ប្រភេទ ស្មើនឹង ២៥.៦០៣ក្បាល

-រៀបចំអាហារដ្ឋានក្អាតចំនួន០២លើក នៅតំបន់អភិរក្សជីវចម្រុះសៀមប៉ាងនិងព្រៃការពារព្រះវិហារ ដោយរាប់ឃើញក្អាតសរុបប្រមាណ៧២ក្បាល

-ការពារសម្បុកត្រយ៉ងចង្កំក ស ចំនួន៣៣ក្បាល ក្អាតចំនួន១០ក្បាល និងរំពេទន្លេចំនួន៧ក្បាល នៅតំបន់សៀមប៉ាងភាគខាងលិច តំបន់ទន្លេមេគង្គលើ និងអាងត្រពាំងថ្ម។

### ៤.៤ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន២១លើក ស្តីពីប្រកាសការរៀបចំគ្រប់គ្រងតំបន់អភិរក្សសត្វខ្សឹប សកម្មភាពអភិរក្សសត្វក្រៀល និងប្រព័ន្ធអេកូឡូស៊ីរួមនិងការគ្រប់គ្រងធនធានធម្មជាតិដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន២០៧នាក់ ស្រី៤០នាក់។

### ៤.៥ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្អាម និងការសង្គ្រោះសត្វព្រៃ

-ក្នុងខែឧសភា ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សា៖ សត្វចំណូលថ្មីចំនួន៣២ក្បាល សត្វដោះលែងចំនួន១១១ក្បាល សត្វស្លាប់ចំនួន២ក្បាល ព្យាបាលសត្វចំនួន២៣ក្បាល យកសំណាកទៅពិសោធន៍ចំនួន៩ក្បាល ធ្វើឲ្យសន្លប់ចំនួន១៦ក្បាល ទម្លាក់សត្វល្អិតចំនួន៨ក្បាល សាងសង់របងហ៊ុំព័ទ្ធនិងទ្រុងសត្វថ្មីចំនួន១.៦០០ម២ ជួសជុលទ្រុងសត្វនិងអគារផ្សេងចំនួន១៤ម២ ជួសជុលផ្លូវចំនួន៨០០ម២ សាងសង់សំណង់ផ្សេងៗចំនួន៣០ម២ ថ្លារអនាម័យព្រៃចំនួន៨០០ម២ ដាំកូនឈើចំនួន១២៥ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៤២២នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥៦.៨១១ក្បាល។

**៤.៦ គម្រោងអភិរក្សសត្វក្រពើកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ**

-បន្តថែរក្សាកូនក្រពើចំនួន២៦ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្ពាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង។

**៤.៧ ការងារដាំដើមឈើ**

-ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីព្រៃសរុបចំនួន៧០ហិកតា បណ្តុះកូនឈើចំនួន១.៩៣២.៦១៨ដើម និងចែកចាយចំនួន៨៨.២៧៤ដើម។

**៤.៨ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើកែច្នៃចំនួន ១២.៧៨៧,៩៩៦ម៣

-ទទួលប្រកាសអនុញ្ញាតឲ្យបង្កើតរោងម៉ាស៊ីនកែច្នៃឈើចំនួន០១ច្បាប់

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០១ស្មើនឹង៨៤សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន១៤.៣៨៤,២៧៤ម៣ ។

**៤.៩ ការងារនីតិកម្មនិងវិវាទ**

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសសរុបចំនួន១៧៨ករណី ដោយបញ្ជូនទៅតុលាការសរុបចំនួន១៥៤ករណី និងពិន័យអន្តរការណ៍ចំនួន ២៤ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១១១,៨៣២ម៣ ឈើអារចំនួន ៤១៧,៥០២ម៣ ឈើក្រាក់គ្រញូងចំនួន៨,៩៩៤ម៣ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត ដូចជា រថយន្តចំនួន៩២គ្រឿង ត្រាក់ទ័រ៨គ្រឿង អេស្កាវ៉ាទ័រ១គ្រឿង រទេះ២គ្រឿង ទូក៣គ្រឿង រណារយន្ត៧គ្រឿង ម៉ូតូ៤៧គ្រឿង កាំបិតចំនួន១៤ ម៉ាស៊ីនផ្សេងៗចំនួន៩គ្រឿង ព្រមទាំងដកហូតដីព្រៃឈើចំនួន១៥០,២០០ហិកតា។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន១៩.០០០តោន ស្មើ១២៦,៦៧% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន២០.០០០តោន សរុបបានចំនួន១៦០.០០០តោន ស្មើ៤១,០៣% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន៤៥.០០០តោន ស្មើ ២៥% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០តោន ។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤

អនុវត្តក្នុងខែចំនួន៨.០០០តោន បានសរុបចំនួន៤៨.០០០តោន ស្មើ៤៣,៦៤% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន។

### ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន១០.០០០តោន សរុបបានចំនួន៤០.០០០តោន ស្មើ៤០% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន

-ការចិញ្ចឹមក្រពើ ក្នុងខែចំនួន១៥.០០០ក្បាល សរុបបានចំនួន៦០.០០០ក្បាល ស្មើ២០% នៃផែនការ ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២៥.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួន២០.០០០.០០០កូន សរុបបានចំនួន៥០.០០០.០០០កូន ស្មើ២៧,៧៨% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន៥.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៣.០០០តោន សរុបបានចំនួន២៨.០០០តោន ស្មើ១៨,៦៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន៤.៥០០តោន ស្មើ៥៦,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣០០តោន

-ការផលិតទឹកត្រី ក្នុងខែចំនួន១០.០០០.០០០លីត្រ សរុបបានចំនួន៣៥.០០០.០០០លីត្រ ស្មើ៥៨,៣៣% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ ក្នុងខែចំនួន៨០០តោន សរុបបានចំនួន៤.៥០០តោន ស្មើ២២,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០០តោន

-ផលនេសាទកែច្នៃ ក្នុងខែចំនួន៤០០តោន សរុបបានចំនួន២.៥០០តោន ស្មើ២៥% នៃផែនការ១០.០០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន១.០៤៦ករណី ដែលកើតមាននៅតំបន់ទឹកសាប១.០១០ករណី និងតំបន់សមុទ្រ ៣៦ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៩ករណី គឺតំបន់ទឹកសាបថយចុះ៤០ករណីនិងតំបន់សមុទ្រកើនឡើង១ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល ក្នុងខែចំនួន១៣៨.៨១៨.៥០០រៀល សរុបបានចំនួន១.៨៦៦.៣៩៨.៧៥០រៀល ស្មើ៦១,៣៨% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៦០០.៣៨២.០៥៣រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចុះប្រមូលព័ត៌មាននិងទិន្នន័យស្តីពីការទទួលយកពូជស្រូវ១០ពូជ នៅខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

-ចុះត្រួតពិនិត្យ វាយតម្លៃការងារពិសោធន៍ និងបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលផ្សព្វផ្សាយឃុំ ស្តីពីបច្ចេកទេសសម្រិតសម្រាំងគ្រាប់ពូជស្រូវចំនួន៣វគ្គ នៅខេត្តស្វាយរៀង និងរៀបចំទិវាស្រែបង្ហាញចំនួន១លើក ដែលមានអ្នកចូលរួមសរុបចំនួន១១៥នាក់

-ធ្វើទិវាស្រែបង្ហាញចំនួន១លើក ដែលមានអ្នកចូលរួមសរុបចំនួន៤០នាក់ និងធ្វើការប្រមូលផលស្រូវពិសោធន៍នៅខេត្តកំពង់ស្ពឺ។

## ៧ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៩១ច្បាប់ សរុបចំនួន២.៣០៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៥៣ច្បាប់ សរុបចំនួន១.៧៦៧ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១០៥ច្បាប់ សរុបចំនួន៥៤៨ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦៦៧ច្បាប់ សរុបចំនួន៣.៦២១ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៦៨ច្បាប់ សរុបចំនួន២២៤ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៤០ច្បាប់ សរុបចំនួន៣៥០ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៦០នាក់ នារីចំនួន១.២៨៥នាក់ ស្មើនឹង១៩% ក្នុងនោះ៖

-អង្គភាពថ្នាក់កណ្តាលចំនួន៤.១១៨នាក់ ក្នុងនោះនារីចំនួន៧៤៦នាក់ ស្មើនឹង១៨,១១%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៤២នាក់ ក្នុងនោះនារីចំនួន៥៣៩នាក់ ស្មើនឹង២០,៤០%

-ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន៩នាក់ ក្នុងនោះបោះបង់ការងារចំនួន៣នាក់ សុំលាឈប់ពីការងារចំនួន៤នាក់ និងមរណភាពចំនួន២នាក់

-ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៤នាក់ ផ្ទេរចូលក្រសួងចំនួន១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៨នាក់

-ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៨នាក់ និងចូលធ្វើការងារវិញចំនួន៣នាក់

-បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៣៧នាក់ នៅក្នុងប្រទេសចំនួន៩

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា

-បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សាសរុបចំនួន៦៦នាក់ នៅក្នុងប្រទេសចំនួន៩។

## ៩ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.២៦៣នាក់(ស្រី៤៤៣នាក់)ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សាលាជាតិកសិកម្មព្រែកលៀបបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងបណ្តុះបណ្តាលបច្ចេកទេសដាំដុះឈើហូបផ្លែនិងបន្លែ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនហ្វ៊ីវវើង នៃខេត្តក្វាងស៊ី ។

### ៩.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ៩.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៧៩២នាក់ (ស្រី១.៣៦៤នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល

បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមស្ថានភាពការងារបង្កបង្កើនផលស្រូវនាដើមរដូវវស្សាឆ្នាំ២០១៤ ត្រូវបានគត់សម្គាល់ឃើញថា ទឹកភ្លៀងនៅមិនទាន់ធ្លាក់រាយប៉ាយគ្រប់តំបន់ទូទាំងប្រទេសនៅឡើយ។ ដោយឡែកក្នុងខែនេះ ខេត្តមួយចំនួនទទួលបានភ្លៀងច្រើនធ្វើឲ្យការងារបង្កបង្កើនផលដំណាំស្រូវមានសន្ទុះលឿនជាងឆ្នាំមុន បើប្រៀបធៀបរយៈពេលដូចគ្នា។ ទន្ទឹមនឹងនោះ ប្រជាកសិករកំពុងសកម្មក្នុងការងារបង្កបង្កើនផលដំណាំរដូវវស្សា ជាពិសេសខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដក ស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ដោយឡែក ចំពោះជំងឺឆ្លងលើសត្វពាហនៈ និងជំងឺឆ្លងភាគត្បាតផ្សេងៗពុំមានចោទជាបញ្ហានិងគ្មានការផ្ទុះឡើងនូវជំងឺគ្រុនផ្តាសាយបក្សីទេ។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទតឹងតែង ស្មុគស្មាញ ហើយដែលត្រូវតែខិតខំបន្តសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។ លើសពីនេះទៅទៀតផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## V- ទិសដៅ

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអត្យុភាពស្ងួត (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ជំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវប្រាំង ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍ជាយថាហេតុដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំផ្សេងៗ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាបន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទេ្វភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្លាកការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវជីកបឹងហួតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយគ្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ការកែច្នៃផលនេសាទទឹកសាប ការកែច្នៃផលនេសាទសមុទ្រ ការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដានិងរុក្ខទិវា៩កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផលនិងព្រៃឈើ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-ទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារ

បច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀត និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង និងការរៀបចំប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីសម្រាប់ឆ្នាំ២០១៤

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**